**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# ញត្តិគាំទ្រ
## សម្តេចតេជោ និងថ្កោលទោសសកម្មជនជ្រុលនិយម

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមគាំទ្រ **សម្តេចតេជោ** និងថ្កោលទោសសកម្មជនជ្រុលនិយមដែលមានឥរិយាបថ និងសម្តីជម្លើយរបស់ជនពាល ៣រូប ដែលតាំងខ្លួនជាអ្នកអធិប្បាយឈឺឆ្អាលរឿងរ៉ាវប្រទេសជាតិ ជ្រកខ្លួនអាស្រ័យដំបូលក្រោមទំព័រហ្វេសប៊ុក។ ជាក់ស្តែងថ្មីៗនេះ ជនទាំង៣ រួមទាំងបុគ្គលអែបអបបំប៉ោងឈ្មោះខ្លួនជា **សម្តេច** ដែលសកម្មខាងបំពុលបណ្តាញសង្គមជាប្រចាំផងនោះ បាននិយាយផ្តាញ់ផ្តាលឌឺដងគ្នាទៅវិញទៅមក ដោយប្រើពាក្យសម្តី និងកាយវិការរបៀបសកម្មជនជ្រុលនិយមមកលើ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ដែលជាបិតាសន្តិភាព និងជាអគ្គមគ្គុទេសក៍ឯកដ៏ឆ្នើមក្នុងការធ្វើនយោបាយដឹកនាំរបស់ជាតិ និងប្រជាជនខ្មែរ។

សម្រាប់ជាតិ និងប្រជាជនខ្មែរ រួមទាំងយើងខ្ញុំទាំងអស់គ្នា **សម្តេចតេជោ** ជាវីរបុរសជាតិ ជាបិតាសន្តិភាព ជាវីរជនផ្សះផ្សាបង្រួបបង្រួមជាតិ ជានិមិត្តរូបនៃការតស៊ូ ដែលបានប្រែក្លាយទឹកដីខ្មែរដែលធ្លាប់បែកបាក់ និរាសព្រាត់ប្រាស ធ្លាក់ដល់ចំណុចសូន្យដោយសារភ្លើងសង្គ្រាមប្រមាណជាង៣០ឆ្នាំ រហូតបានក្លាយជាប្រទេសដែលមានអធិបតេយ្យភាព ប្រជាជនមានស្នាមញញឹមនិងក្តីសង្ឃឹម និងរស់នៅប្រកបដោយសុខសន្តិភាពដូចសព្វថ្ងៃ។ មិនតែប៉ុណ្ណោះ **សម្តេចតេជោ** ជាឥស្សរជនជាន់ខ្ពស់ដ៏ឆ្នើមមួយរូប ដែលទទួលបានការគោរព កោតសរសើរ និងស្ញប់ស្ញែងជាទីបំផុត បានតស៊ូសិក្សារៀនសូត្រ ពីកូនកសិករ ពីក្មេងវត្ត ទៅជានាយករដ្ឋមន្ត្រី ជាប្រធានព្រឹទ្ធសភា ជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជា ដែលបានប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី មិនខ្លាចនឿយហត់យកជីវិតធ្វើជាដើមទុន និងហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍធនធានមនុស្សប្រកបដោយសក្តានុពល ធ្វើឱ្យជាតិមានការរីកចម្រើនជឿនលឿនគ្រប់វិស័យ។

ក្នុងន័យនេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រកាសថ្កោលទោសយ៉ាងដាច់អហង្ការ និងចាត់ទុកទង្វើអន្ធពាល ជ្រុលនិយមរបស់ជនពាលទាំង៣រូបនោះ ជាការសាបព្រោះមនោគមវិជ្ជាបរទេសនិយមជ្រុលដ៏កង្វក់ជាទីបំផុត ដែលតែងតែប្រើវិធីសាស្ត្រលាបពណ៌ ញុះញង់ និងបំបែកបំបាក់សាមគ្គីភាព និងសុខសន្តិភាពរបស់ប្រទេសជាតិ។

ថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤